**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខៈ.....០០៦/០៩...... កប/ប.ក

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍

+++

**រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការបញ្ចប់តំណែងរាជរដ្ឋាភិបាល និងការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០១០០/០០៧ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើត អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បកចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**<u>ស ម្រេ ច</u>**

**ប្រការ ១.-**

បង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ហៅកាត់ថា "**គ.ប.អ**" ។ **គ.ប.អ** មានគោលដៅសម្របសម្រួលផ្នែកបង្ការ និងប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ សំរាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ប្រការ ២.-**

**គ.ប.អ មានសមាសភាពដូចតទៅ÷**

| | | | |
|---|---|---|---|
| ១.ឯកឧត្តមវេជ្ជ. | **ហ៊ុយ ហានសុង** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២. ឯកឧត្តម | **អៀង សុផល** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣.ឯកឧត្តម | **ម៉ុន តារិន** | នាយកវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) | សមាជិក |
| ៤. លោក | **អ៊ុក ដារ៉ា** | នាយកវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម (ITI) | សមាជិក |
| ៥. លោក | **ម៉ាន់ ណារ៉ា** | នាយកមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-[illegible] | សមាជិក |
| ៦. លោក | **សាលី មុនី** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |
| ៧. លោកស្រី | **ជា សុខនី** | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម | សមាជិក |

| | | | |
|---|---|---|---|
| ៨. លោក | គីម ធីមិត្ត | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៩. លោក | គាម ម៉ារិទ្ធីយ៉ា | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១០. លោក | ជុំ ម៉ុំ | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១១. លោក | គួច ឧុត្តី | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១២. លោក | ជួរ អឿនលី | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | សមាជិក |
| ១៣. លោក | ជួប ណារ៉ាត់ | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | សមាជិក |
| ១៤. លោក | សួន ស៊ីធឿន | នាយករងរបបបេឡាសន្តិសុខសង្គម | សមាជិក |
| ១៥. លោកស្រី | នុង សុភាព | អនុប្រធាននាយកដ្ឋានការងារកុមារ | សមាជិក |
| ១៦.លោកវេជ្ជ. | ឈឹម យុទ្ធសំភី | អនុប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ១៧. លោក | ហ៊ឹង ស៊ីដេត | អនុប្រធាននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ | សមាជិក |
| ១៨. លោក | គួន គីម៉ាឡែន | អនុប្រធាននាយកដ្ឋានស្តង់ដារជាតិសមត្ថភាព | សមាជិក |
| ១៩. លោក | គង់ ច័ន្ទតារា | អនុប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារ | សមាជិក |
| ២០. លោកស្រី | ម៉ៅ ធីតា | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ២១. លោក | ឡាច សុជាតិ | នាយករងវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ (NIB) | សមាជិក |
| ២២. លោក | សៅ ឌី | នាយករងវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសមៈ (PPI) | សមាជិក |
| ២៣. លោក | យ៉ោក សុទ្ធី | នាយករងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (NTTI) | សមាជិក |
| ២៤. លោក | ឈាង ចិសាល | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |
| ២៥.លោក | អ៊ុំ ធីរៈ | ប្រធានការិយាល័យនៃនាយកដ្ឋានព័ត៌មានទីផ្សារការងារ | សមាជិក |
| ២៦.លោក | សំ សុផល | អនុប្រធានការិយាល័យនៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |
| ២៧. លោកស្រី | កង ឌីធីន | អនុប្រធានការិយាល័យនៃនាយកដ្ឋានវិវាទការងារ | សមាជិក |
| ២៨. លោកស្រី | អៀង សុចន្ធី | អនុប្រធានការិយាល័យនៃនាយកដ្ឋាន TVET | សមាជិក |
| ២៩. កញ្ញា | គីម សិរីរត្នន៍ | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |

**ប្រការ ៣.-**

**ភារកិច្ចរបស់ គ.ប.អ មានជាអាទិ៍ ដូចតទៅ ÷**

១.ជាសេនាធិការឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីសិក្សាស្រាវជ្រាវ បង្កើតផែនការយុទ្ធសាស្ត្រ ផែនការការងារ និងអនុវត្តនូវសកម្មភាពកម្មវិធីអេដស៍ ទៅដល់មន្ត្រីរាជការស្ថិតនៅក្រោមឱវាទក្រសួង ពលករទេសន្តរប្រវេសន៍ សិស្ស និស្សិតនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ស្ថាប័ន និងសហគមន៍ពាក់ព័ន្ធ ។

២.ចូលរួមសហការសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីស្វែងរកប្រភពធនធាន ថវិកា សម្ភារៈ បច្ចេកទេសពីអង្គការជាតិ អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តផែនការសកម្មភាពឱ្យបានជោគជ័យ ។

៣. រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយដល់ពលករចល័តទាំងក្នុង និងក្រៅប្រទេស មុនពេលចាកចេញ និងពេលត្រឡប់មកវិញ ដើម្បីទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ជាពិសេសពលករដែលបានទៅបំពេញការងារនៅក្រៅប្រទេស ។

៤. បង្កើនការចូលរួមយ៉ាងសកម្ម របស់អ្នកផ្ទុកមេរោគអេដស៍ និងអ្នករងផលប៉ះពាល់ ដើម្បីប្រយុទ្ធនឹងជំងឺអេដស៍ ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់មន្ត្រីរាជការស្ថិតនៅក្រោមឱវាទក្រសួង ។/.

៥. ផ្តល់ការគាំទ្រដល់ស្ត្រី/កុមារ ដែលផ្ទុកមេរោគអេដស៍ /ជំងឺអេដស៍ ទាំងផ្នែក ស្មារតី និងសំភារៈ ។

៦.ត្រួតពិនិត្យ និងវាយតំលៃលើលទ្ធផលអនុវត្តគោលនយោបាយ គោលការណ៍ ផែនការកម្មវិធីបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ និងបូកសរុបលទ្ធផលការងារអេដស៍ប្រចាំឆ្នាំ ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

**ប្រការ ៤.-**

-**គ.ប.អ** ធ្វើការប្រជុំតាមការអញ្ជើញរបស់ប្រធាន

-**គ.ប.អ**ត្រូវប្រជុំជាសាមញ្ញរៀងរាល់មួយត្រីមាសម្តង និងអាចប្រជុំជាវិសាមញ្ញតាមការចាំបាច់

-ប្រធានអាចអញ្ជើញស្ថាប័នពាក់ព័ន្ធផ្សេងៗ និងតំណាងភ្នាក់ងារអង្គការក្រៅរដ្ឋាភិបាលជាតិ/អន្តរជាតិ អង្គការនិយោជក អង្គការសហជីព អ្នកផ្តល់ជំនួយ ចូលរួមកិច្ចប្រជុំពិភាក្សាការងារលើឯកសារពាក់ព័ន្ធ ។

**ប្រការ ៥.-**

**គ.ប.អ** អាចលើកសំណើជូនថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការជ្រើសរើសមន្ត្រីអនុវត្តគំរោង ក្នុងករណីចាំបាច់ ។

**ប្រការ ៦.-**

**គ.ប.អ** មានសិទ្ធិប្រើត្រារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអនុវត្តការងាររបស់ខ្លួន ។

**ប្រការ ៧.-**

**គ.ប.អ** មានលេខាធិការដ្ឋានអចិន្ត្រៃមួយ នៅជាមួយលេខាធិការដ្ឋានគណៈកម្មការសំរបសំរួលត្រីភាគី ។

**ប្រការ ៧.-**

ប្រកាសលេខ ២១៦ ក.ក.ប.វ/ប្រ.កចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៧ ប្រកាសលេខ០២៤កប/ប្រក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០០៨ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន និងគ្រប់ប្រធានមន្ទីរស្ថិតក្រោមឱវាទក្រសួង ស្ថាប័នពាក់ព័ន្ធ និងលោក លោកស្រី ដូចមានចែងក្នុងប្រការ **២** មានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ,ថ្ងៃទី១៩ ខែមករា ឆ្នាំ ២០០៩

រដ្ឋមន្ត្រី

**វង សូត**

<u>**ចម្លងជូន**</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម និងលោកជំទាវឧបនាយករដ្ឋមន្ត្រី
-អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
-គ្រប់ក្រសួងពាក់ព័ន្ធ
**"ដើម្បីជូនជ្រាប"**
-គ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
**"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"**
-សមាគមនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា
-សហព័ន្ធសហជីព **"ដើម្បីជ្រាប"**
-គ្រប់បណ្តាញវិទ្យុ ទូរទស្សន៍ **"ដើម្បីជួយផ្សព្វផ្សាយ"**
-ដូចប្រការ ២ **"ដើម្បីអនុវត្ត"**
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ